**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**អាជ្ញាធរសវនកម្មជាតិ**

លេខៈ ០៦៧/០៣អសជ/សវស

# សេចក្តីសំរេច

## ស្តីពី

## សវនកម្មគណនី និងសវនកម្មប្រតិបត្តិការរបស់ឃុំ-សង្កាត់

## អគ្គសវនករ នៃអាជ្ញាធរសវនកម្មជាតិ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣០០/១០ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០០ ដែលប្រកាសអោយប្រើច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ-សង្កាត់
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០១/២៥៨ ចុះថ្ងៃទី ៥ ខែ សីហា ឆ្នាំ ២០០១ ស្តីពីការតែងតាំងអគ្គសវនករ អគ្គសវនកររង នៃអាជ្ញាធរសវនកម្មជាតិ
- យោងអនុក្រឹត្យលេខ ១៦ អនក្រ.បក ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០០២ ស្តីពីមូលនិធិឃុំ-សង្កាត់
- យោងអនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០០២ ស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុឃុំ-សង្កាត់

## សំរេច

**ប្រការ ១ :** កំណត់នីតិវិធីនៃការធ្វើសវនកម្មផ្ទៃក្រៅលើគណនី និងប្រតិបត្តិការរបស់ឃុំ-សង្កាត់អនុលោមតាមច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា និងតាមជំពូកទី៧ មាត្រា៨៦ នៃអនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០០២ ស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុឃុំ-សង្កាត់ ។

**ប្រការ ២ :** ការធ្វើសវនកម្មដោយអនុលោមតាមស្តង់ដារនៃការធ្វើសវនកម្មទូទៅ ជាពិសេសៈ

១. អាជ្ញាធរសវនកម្មជាតិមានភាពឯករាជ្យពេញលេញក្នុងការអនុវត្តន៍ ការវិនិច្ឆ័យ បញ្ចេញយោបល់ និងផ្តល់អនុសាសន៍ដោយគ្មានលំអៀង

២. សវនករប្រកាន់ខ្ជាប់នូវក្រមសីលធម៌វិជ្ជាជីវៈសវនកម្ម

៣. អាជ្ញាធរសវនកម្មជាតិមានឯកសារភស្តុតាងគ្រប់គ្រាន់ ពាក់ព័ន្ធ និងអាចជឿជាក់បាន សំរាប់ជាមូលដ្ឋានក្នុងការសន្និដ្ឋាន និងផ្តល់អនុសាសន៍ ។

**ប្រការ ៣ :** ការធ្វើសវនកម្មឃុំ-សង្កាត់ហៅកាត់ថា **"សវនកម្ម"** រួមមាន ការត្រួតពិនិត្យលើភាពត្រឹមត្រូវជាក់លាក់ គ្រប់គ្រាន់ សុពលភាព និងភាពសមស្របនៃទិន្នន័យដែលមាននៅក្នុងរបាយការណ៍ហិរញ្ញវត្ថុឃុំ-សង្កាត់ ក្នុងគោលបំណង ដូចខាងក្រោម :

- ធ្វើអោយប្រាកដថា ពត៌មានដែលបានបញ្ចូលទៅក្នុងរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំរបស់ឃុំ- សង្កាត់ ពិតជាត្រឹមត្រូវ និងអាចជឿជាក់បាន
- វាយតំលៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងឃុំ-សង្កាត់ និងភាពអនុលោមជាមួយ ច្បាប់ បទប្បញ្ញត្តិ នីតិវិធីនៃការគ្រប់គ្រងជាធរមាន
- ក្នុងករណីចាំបាច់ ត្រូវផ្តល់អនុសាសន៍ដើម្បីកែលំអប្រព័ន្ធពត៌មានហិរញ្ញវត្ថុឃុំ-សង្កាត់ និងនីតិវិធីត្រួតពិនិត្យផ្ទៃក្នុង ។

**ប្រការ ៤ :** ប្រធានក្រុមប្រឹក្សាឃុំ-សង្កាត់និងប្រធានរតនាគារខេត្ត-ក្រុងមានកាតព្វកិច្ចបង្កលក្ខណៈងាយស្រួលដល់អាជ្ញាធរសវនកម្មជាតិ ដើម្បីមានសិទ្ធិគ្រប់គ្រាន់ក្នុងការពិនិត្យបញ្ជីកាគណនេយ្យ ទ្រព្យសម្បត្តិ និងបុគ្គលិកព្រមទាំងពត៌មានទាំងឡាយ ដែលរក្សាទុក ឬស្ថិតក្រោមសមត្ថកិច្ចរបស់ក្រុមប្រឹក្សាឃុំ-សង្កាត់ និងរតនាគារខេត្ត-ក្រុង ។

**ប្រការ ៥ :** ដំណើរការសវនកម្មត្រូវអនុវត្តដូចខាងក្រោមៈ

១. អាជ្ញាធរសវនកម្មជាតិរៀបចំនិងអនុវត្តនីតិវិធីអោយបានសមស្របដើម្បីបញ្ចេញមតិលើរបាយការណ៍ហិរញ្ញវត្ថុឃុំ-សង្កាត់នៃខេត្ត-ក្រុងនីមួយៗ និងភាពគ្រប់គ្រាន់នៃរចនាសម្ព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរបស់ឃុំ-សង្កាត់

២. សវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុឆ្នាំមុន ត្រូវចាប់ផ្តើមពីខែមីនានៃឆ្នាំបន្ទាប់

៣. សវនកររៀបចំផែនការសកម្មភាពរួមមាន ប្រតិទិនការងារ និងទីកន្លែងដែលត្រូវធ្វើសវនកម្មនៅ តាមឃុំ-សង្កាត់ និងរតនាគារខេត្ត-ក្រុង

៤. ក្នុងករណីចាំបាច់សវនករអាចអញ្ជើញមេឃុំ-ចៅសង្កាត់ឡើងមកទីរួមខេត្ត-ក្រុងដើម្បីស្នើសុំពតិមានបន្ថែម ។

**ប្រការ ៦ :** អាជ្ញាធរសវនកម្មជាតិរៀបចំរបាយការណ៍សវនកម្មសំរាប់ឃុំ-សង្កាត់នីមួយៗផ្អែកលើឯកសារ ភស្តុតាងគ្រប់គ្រាន់ ពាក់ព័ន្ធ និងអាចជឿជាក់បាន រួមមាន ដូចខាងក្រោម :

- ការធ្វើតេស្ត និងត្រួតពិនិត្យលើការងារសវនកម្មដែលបានអនុវត្ត
- ការវាយតំលៃលើសុពលភាព ភាពគ្រប់គ្រាន់ និងភាពត្រឹមត្រូវជាក់លាក់នៃបញ្ជីកាគណនេយ្យ និងរបាយការណ៍ហិរញ្ញវត្ថុព្រមទាំងផ្តល់មតិលើភាពពិត និងភាពត្រឹមត្រូវនៃរបាយការណ៍
- ការវាយតំលៃលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង
- ការអនុលោមស្របទៅតាមបទប្បញ្ញត្តិ និងល័ក្ខខ័ណ្ឌនៃកិច្ចសន្យា
- អនុសាសន៍របស់សវនករ ។

របាយការណ៍សវនកម្មត្រូវបញ្ចូលផងដែរនូវមតិពាក់ព័ន្ធជាលាយល័ក្ខអក្សររបស់ប្រធានក្រុមប្រឹក្សាឃុំ-សង្កាត់ ប្រធានរតនាគារខេត្ត-ក្រុង និងអភិបាលខេត្ត-ក្រុងចំពោះលទ្ធផលសវនកម្ម និងការផ្តល់អនុសាសន៍របស់អាជ្ញាធរសវនកម្មជាតិ ។

អាជ្ញាធរសវនកម្មជាតិត្រូវផ្តល់របាយការណ៍សវនកម្មនេះជូនទៅ :

- ប្រធានក្រុមប្រឹក្សាឃុំ-សង្កាត់ពាក់ព័ន្ធ
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- អង្គភាពពាក់ព័ន្ធដែលអាជ្ញាធរសវនកម្មជាតិយល់ឃើញថាចាំបាច់ ។

**ប្រការ ៧ :** ក្រុមប្រឹក្សាឃុំ-សង្កាត់ មានកាតព្វកិច្ចដូចខាងក្រោម :

- តំកល់របាយការណ៍សវនកម្មនៅសាលាឃុំ-សង្កាត់សំរាប់ពតិមានជាសាធារណៈ
- ត្រូវចាត់វិធានការកែលំអចាំបាច់ដើម្បីអនុវត្តអនុសាសន៍សវនកម្ម ។

**ប្រការ ៨ :** ក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួង-ស្ថាប័នពាក់ព័ន្ធនានា ត្រូវមានកាតព្វកិច្ចចាត់វិធានការជាក់ស្តែងដើម្បីអនុវត្តអោយមានប្រសិទ្ធភាពតាមអនុសាសន៍សវនកម្មដោយផ្សារភ្ជាប់នឹងប្រព័ន្ធហិរញ្ញវត្ថុឃុំ-សង្កាត់ ។

**ប្រការ ៩** : អគ្គលេខាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋាននានាចំណុះអោយអាជ្ញាធរសវនកម្មជាតិ ក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួង-ស្ថាប័ន រដ្ឋបាលខេត្ត-ក្រុង រដ្ឋបាលមូលដ្ឋាន និង អង្គភាពពាក់ព័ន្ធ មានភារកិច្ចទទួលខុសត្រូវ ក្នុងការអនុវត្តន៍តាមប្រការទាំងឡាយនៃសេចក្តីសំរេចនេះ។

**ប្រការ ១០** : សេចក្តីសំរេចនេះ មានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ភ្នំពេញ ថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០០៣

**អគ្គសវនករ**

**អ៊ុត ឈួន**

**__ចំលងជូន:__**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី

  " ដើម្បីជូនជ្រាប"
- គណៈកម្មាធិការដឹកនាំការងារនៃកម្មវិធីសិលា
- ដូចប្រការ៩

  " ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ